ក្រសួងអប់រំ យុវជន និងកីឡា

សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច

# ការបែងចែកដីធ្លីឡើងវិញ និងជោគជ័យរបស់វា

# (Land Redistribution and Its Success)

ឃាប់ ផល្លី

ខែកញ្ញា ឆ្នាំ២០០៩

# មាតិកា

- ដីរដ្ឋ
- គោលបំណងនៃការបែងចែកដីធ្លីឡើងវិញ
- កម្មវិធីបែងចែកដីធ្លីតាមរយៈសម្បទានដីសង្គមកិច្ច
- បញ្ហាប្រឈម
- តម្រូវការក្នុងការបែងចែកដីធ្លីឱ្យបានជោគជ័យ
- សេចក្ដីសន្និដ្ឋាន

# ដីរដ្ឋ (១)

- **រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា (ម. ៥៨)**

  -មិនបានបែងចែកប្រភេទដីរដ្ឋជាដីឯកជនរបស់រដ្ឋ ឬដីសាធារណៈរបស់រដ្ឋ ។

- **ច្បាប់ភូមិបាលឆ្នាំ២០០១ (ម. ១៥) សរសេរកាត់ជា (ចភ. ម.១៥)**

  -ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

  (មិនបានចែកឱ្យដាច់ថាទ្រព្យណាមួយជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ

  និងណាមួយជាទ្រព្យសម្បត្តិសាធារណៈរបស់នីតិបុគ្គលសាធារណៈ) ។

# ដីរដ្ឋ (២)

- ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ

-មិនអាចលក់ដូរ (ចភ. ម. ១៦)

-មិនមានកំណត់អាជ្ញាយុកាលអំពីកម្មសិទ្ធិរបស់ទ្រព្យនេះ (ចភ. ម. ១៦)

-ជាកម្មវត្ថុនៃការកាន់កាប់ ប្រើប្រាស់បណ្តោះអាសន្ន មិនទៀង ដកហូតបាន

-អាចមានកិច្ចសន្យាជួល តែមិនលើសពី១៥ឆ្នាំ (ម. ១៨ នៃអនុក្រឹត្យស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ, លេខ១២៩អនក្រ/បក/២៧ វិច្ឆិកា ២០០៦ )

# ដីរដ្ឋ (៣)

- **ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ**

-អាចជាកម្មវត្ថុនៃការលក់ដូរ បែងចែក ឬផ្ទេរកម្មសិទ្ធិ (ចភ. ម. ១៧)

-អាចជាកម្មវត្ថុនៃសម្បទាន (ចភ. ម. ១៧)

-រយៈពេលសម្បទានដីមិនឱ្យលើសពី៩៩ឆ្នាំ (ចភ. ម. ៦១)

- **ទ្រព្យសម្បត្តិឯកជនរបស់នីតិបុគ្គលសាធារណៈ**

-ជាកម្មវត្ថុនៃកិច្ចការជំនួញ (ចភ. ម. ១៤)

-អាចជាកម្មវត្ថុនៃការលក់ដូរ បែងចែក ឬផ្ទេរកម្មសិទ្ធិ (ចភ. ម. ១៧)

# សកម្មភាព១

តាមយោបល់របស់អ្នក តើត្រូវធ្វើដូចម្តេចដើម្បីគ្រប់គ្រងជីវជ្ជឱ្យមាន

ប្រសិទ្ធភាព?

# គោលបំណងនៃការបែងចែកដីធ្លីឡើងវិញ (១)

- បែងចែកទ្រព្យសម្បត្តិរបស់រដ្ឋប្រកបដោយសមធម៌ដល់ពលរដ្ឋក្រីក្រ

-គ្រួសារក្រីក្រដែលគ្មានផ្ទះសំបែងសម្រាប់សង់លំនៅឋាន

-គ្រួសារក្រីក្រសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ

-គ្រួសារដែលត្រូវផ្លាស់ប្តូរលំនៅដោយសារការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ

-គ្រួសារដែលរងគ្រោះដោយគ្រោះធម្មជាតិ

-គ្រួសារមាតុភូមិនិវត្ត

-យោធិនរំសាយ និងគ្រួសារយុទ្ធជនពលី ពិការ ។

# គោលបំណងនៃការបែងចែកដីធ្លីឡើងវិញ (២)

- **អភិវឌ្ឍសេដ្ឋកិច្ចជាតិ**

-ជួយសម្រួលដល់ការអភិវឌ្ឍសេដ្ឋកិច្ច

-ជួយសម្រួលដល់សម្បទានដីសេដ្ឋកិច្ច ដោយផ្តល់ដីឡូតិ៍ដល់កម្មករចម្ការធំៗសម្រាប់សង់លំនៅឋាន ឬសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ

-អភិវឌ្ឍតំបន់ដែលពុំទាន់ត្រូវបានអភិវឌ្ឍសមស្រប

(មាត្រា៣នៃអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច, លេខ១៩អនក្រ/បក/១៩ មីនា ២០០៣)

# កម្មវិធីបែងចែកដីធ្លីតាមរយៈសម្បទានដីសង្គមកិច្ច (១)

- កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន

ក្រុមប្រឹក្សាឃុំ-សង្កាត់ → ក្រុមការងារថ្នាក់ស្រុក-ខណ្ឌ → គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង

↓ ជូនដំណឹងពីការយល់ព្រម

គណៈកម្មាធិការសង្គមកិច្ចថ្នាក់ជាតិ

កែសម្រួល ឬលុបចោល

បើមានការខ្វះចន្លោះ (៦០ថ្ងៃ)

# កម្មវិធីបែងចែកដីធ្លីតាមរយៈសម្បទានដីសង្គមកិច្ច (២)

- កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ

ក្រសួង ឬស្ថាប័នផ្តើមសំណើ → គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ

↓

យល់ព្រម

ឬកែសម្រួល

# កម្មវិធីបែងចែកដីធ្លីតាមរយៈសម្បទានដីសង្គមកិច្ច (៣)

- ភារកិច្ចរបស់អ្នកទទួលដីសម្បទានសង្គមកិច្ច

_ដីលំនៅឋាន → សង់ជម្រកក្នុងរយៈពេល៣ខែចាប់ពីពេលបានទទួលដី និងរស់នៅពិតប្រាកដលើសពី៦ខែ/ឆ្នាំ។

↓

១.២០០ម$^{២}$ ឬ៣.៦០០ម$^{២}$ នៅតំបន់មានលទ្ធភាព

_ដីកសិកម្ម → ធ្វើកសិកម្មជាក់ស្តែងក្នុងរយៈពេល១២ខែ បន្ទាប់ពីពេលបានទទួលដី

↓

២ហិកតា ឬ៥ហិកតា នៅតំបន់មានលទ្ធភាព

# សកម្មភាព២

១ តើការដែលរដ្ឋាភិបាលមិនបានកំណត់ទំហំដីអប្បបរមា សម្រាប់គោលដៅសម្បទានដីសង្គមកិច្ច មានផលប៉ះពាល់ដូចម្តេច?

២ តើអ្នកបានជួប ឬឮដូចម្តេចខ្លះពីការលំបាកជាចម្បងរបស់អ្នកដែលត្រូវផ្លាស់ប្តូរលំនៅដោយការអភិវឌ្ឍ?

# បញ្ហាប្រឈម (១)

- ជីវភាពនៅមានកម្រិតទាបរបស់អ្នកទទួលដីសម្បទានសង្គមកិច្ច

  -ឱកាសការងារមានកម្រិត

  -ហេដ្ឋារចនាសម្ព័ន្ធនៅខ្វះខាត

- ការចាកចេញ ឬបោះបង់ពីលំនៅថ្មីរបស់អ្នកទទួលដីសម្បទាន

  -ឆ្ងាយពីកន្លែងធ្វើការងារ

  -ស្វែងរកការងារ

  -ធ្វើឱ្យមានការចំណាយកាន់តែច្រើនទៅលើការធ្វើដំណើរ

# បញ្ហាប្រឈម (២)

- ការបោះបង់ការសិក្សារបស់កូនចៅអ្នកទទួលដីសម្បទានសង្គមកិច្ច

  -ងាយស្រួលក្នុងការទាក់ទាញឱ្យប្រព្រឹត្តអំពើមិនល្អ

  -មិនអាចជួយលើកស្ទួយជីវភាពគ្រួសាររបស់ខ្លួនបាននៅពេលអនាគត

  -បន្ទុកសង្គមកាន់តែធ្ងន់ធ្ងរ

- ការលក់ដូរដីដែលទើបតែទទួលបានពីសម្បទាដីសង្គមកិច្ច

  -ការគ្រប់គ្រងដីធ្លីនៅតំបន់នោះនៅមានការខ្វះចន្លោះច្រើន

  -បង្កឱ្យមានជនគ្មានលំនៅឋានបន្តទៀត

# សកម្មភាព៣

តើអ្នកគិតថា មានបញ្ហាប្រឈមអ្វីខ្លះទៀតទេ ក្រៅពីការលើកឡើងខាងលើនេះ?

# គន្លឹះការក្នុងការបែងចែកដីធ្លីឱ្យបានជោគជ័យ (១)

- រៀបចំរចនាសម្ព័ន្ធមូលដ្ឋានជាមុនសិន

-ផ្លូវ

-ទឹក

-ភ្លើង

-សាលារៀន

-មន្ទីរពេទ្យ ឬមណ្ឌលសុខភាព

-ផ្សារ

# គម្រូការក្នុងការបែងចែកដីធ្លីឱ្យបានជោគជ័យ (២)

- ផ្តល់ការបំប៉នផ្នែកជំនាញវិជ្ជាជីវៈ

  -ជំនាញកសិកម្ម

  -ជំនាញផ្នែកបច្ចេកវិទ្យាផ្សេងៗ

- បង្កើតការងារឱ្យបានច្រើន

  -ជំរុញការវិនិយោគនៅជិតតំបន់ដែលមានការតាំងលំនៅឋានថ្មី

# តម្រូវការក្នុងការបែងចែកដីធ្លីឱ្យបានជោគជ័យ (៣)

- ផ្តល់ប្រាក់កម្ចីដែលមានការប្រាក់ទាប

-ត្រូតពិនិត្យប្រវត្តិរបស់គ្រួសារដែលត្រូវខ្ចីប្រាក់ឱ្យមានភាពច្បាស់លាស់

-គ្រប់គ្រងគោលនយោបាយផ្តល់ប្រាក់កម្ចីឱ្យមានភាពត្រឹមត្រូវ

-ជំរុញឱ្យមានទីផ្សារលើផលិតផលដែលផលិតបាន

- ជំរុញឱ្យកូនចៅបានចូលរៀនគ្រប់ៗគ្នា

-គោលនយោបាយផ្តល់ប្រាក់កម្ចីគួរភ្ជាប់ជាមួយកាតព្វកិច្ចបញ្ជូនកូនចៅទៅសាលារៀន

-អត្រាការសិក្សាត្រូវគ្រប់គ្រងឱ្យបានច្បាស់លាស់

# តម្រូវការក្នុងការបែងចែកដីធ្លីឱ្យបានជោគជ័យ (៤)

- ចំពោះគ្រួសារដែលត្រូវផ្លាស់ប្តូរលំនៅដោយការអភិវឌ្ឍ

-សិក្សាពីទិន្នន័យពិតប្រាកដរបស់គ្រួសារត្រូវផ្លាស់លំនៅ

-ស្រាវជ្រាវពីជំនាញ និងលទ្ធភាពដែលគ្រួសារនីមួយៗមាន

-បំប៉នជំនាញបន្ថែម៖ +ជាងកាត់សក់ ជាងអ៊ុតសក់

+ជាងឈើ ជាងភ្លើង

+ជាងគំនូរ

+ជាងដេរ

# សកម្មភាព៤

១ តើមានមធ្យោបាយអ្វីខ្លះដើម្បីរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធ មូលដ្ឋានជាមុនសិន មុននឹងសម្រេចឱ្យធ្វើការតាំងលំនៅថ្មី?

២ តើអ្នកយល់យ៉ាងណា ចំពោះគោលនយោបាយផ្តល់ប្រាក់កម្ចីដែលមានភ្ជាប់កាតព្វកិច្ចបញ្ជូនកូនចៅទៅសាលារៀន?

# សេចក្តីសន្និដ្ឋាន

- ការគ្រប់គ្រងដីរដ្ឋនៅមិនទាន់មានប្រសិទ្ធភាព។
- គ្រួសារក្រីក្រ ជាពិសេសគ្រួសារគ្មានដីនៅមានច្រើនក្នុងសង្គមជាតិខ្មែរ។
- ការបែងចែកដីធ្លីឡើងវិញតាមរយៈសម្បទានដីសង្គមកិច្ចនៅមានភាពយឺតយ៉ាវ និងមិនទាន់មិនទាន់ឆ្លើយតបនឹងតម្រូវការអភិវឌ្ឍន៍ជាក់ស្តែង។
- ការបែងចែកដីធ្លីឡើងវិញដែលអនុវត្តឱ្យបានតាមគោលការណ៍ដែលមានចែងក្នុងច្បាប់ និងលិខិតបដ្ឋានគតិយុត្តពាក់ព័ន្ធអាចនាំទៅរកការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

# ឯកសារយោង


-ច្បាប់ភូមិបាលឆ្នាំ២០០១, លេខ នស/រកម/០៨០១/១៤/៣០ សីហា ២០០១។

-អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច, លេខ១៩អនក្រ/បក/១៩ មីនា ២០០៣។

-អនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ, លេខ១២៩អនក្រ/បក/២៧ វិច្ឆិកា ២០០៦

-Matthew Rendall et al., *ច្បាប់ភូមិបាលកម្ពុជា-សៀវភៅសិក្សា និងស្រាវជ្រាវ* (ភ្នំពេញ East-West Management Institute, Inc., ខែវិច្ឆិកា ឆ្នាំ២០០៣)។

-សមាគមអាដហុក ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា, ស្ថានភាពសិទ្ធិមនុស្សនៅ ឆ្នាំ២០០១ ដល់២០០៨ (ភ្នំពេញ សមាគមអាដហុក ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)។

# សូមអរគុណ!

## សំណួរ  និងចម្លើយ